ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៤៩ កអ១ហ

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ចូល
លេខ: ១១៥/២៣
ថ្ងៃទី ៣០ ខែ ៣ ឆ្នាំ២០២៣
បញ្ជូនមកពី ...

# កំណត់ហេតុ

ថ្ងៃពុធ ដប់ពីររោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីដប់មួយ ខែតុលា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល នៅសាលប្រជុំខេត្តឧត្តរមានជ័យ ទីស្ដីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិនិត្យ និងពិភាក្សាបន្តលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុច ចាន់ណូរ៉ា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** ។

**+ សមាសភាពអញ្ជើញចូលរួមកិច្ចប្រជុំ ៖**

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ង៉ាង | វ៉ាស៊ី | អនុប្រធានក្រុមប្រឹក្សានីតិកម្ម |
| ២. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ី | សុខឃី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៣. | ឯកឧត្តម | សុខ | លីនណា | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៤. | ឯកឧត្តម ឧត្តមអគ្គានុរក្ស.១ | សន | កែវ | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ |
| ៥. | ឯកឧត្តម | ហួច | លេនីន | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុក្រិត្យ | ថនឥស្សរ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៧. | លោក ឧត្តមសេនីយ៍ទោ | ប៉េង | គង់ | អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៨. | លោក | វង | វីបុទ្ធិ | សមាជិកក្រុមប្រឹក្សានីតិកម្ម |
| ៩. | លោក វរសេនីយ៍ឯក | ខិម | និត្យសត្យា | សមាជិកក្រុមប្រឹក្សានីតិកម្ម |
| ១០. | លោក ឧត្តមសេនីយ៍ត្រី | ខេង | ប៉ូលីដា | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១១. | លោក ឧត្តមសេនីយ៍ត្រី | ឈឹម | សម្បត្តិ | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១២. | លោក វរសេនីយ៍ឯក | សឿ | ឡេលីនដា | អនុប្រធាននាយកដ្ឋាន នៃអគ្គាធិការដ្ឋាន |
| ១៣. | លោក ឧត្តមសេនីយ៍ត្រី | ហេង | បញ្ញាវឌ្ឍន៍ | នាយការិយាល័យ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១៤. | លោក វរសេនីយ៍ទោ | ឆន | ដារ៉ារិទ្ធ | នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៥. | លោក វរសេនីយ៍ឯក | ចែម | ជួន | អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |
| ១៦. | លោក វរសេនីយ៍ទោ | សេង | ផាន់ណា | អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |
| ១៧. | លោក វរសេនីយ៍ទោ | ហ៊ិន | ម៉ារ | នាយរងការិយាល័យ នៃនាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |
| ១៨. | លោក អនុសេនីយ៍ត្រី | ខន | ភារៈបុត្រ | មន្ត្រី នៃនាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តម អ៊ុច ចាន់ណារ៉ា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** និងជាប្រធានអង្គប្រជុំ បានមានប្រសាសន៍ស្វាគមន៍បើកអង្គប្រជុំ និងណែនាំពីចំណុចសំខាន់ៗមួយចំនួន ដើម្បីមានមូលដ្ឋានក្នុងការពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ។

ជាកិច្ចបន្ត **ឯកឧត្តមប្រធានអង្គប្រជុំ** បានប្រគល់ភារកិច្ចជូនការីកុំព្យូទ័រ ដើម្បីបង្ហាញខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នា ចាប់ពីមាត្រា៧ ដល់មាត្រា១៤ ជូនអង្គប្រជុំពិនិត្យ ពិភាក្សាបន្ត ។

ក្រោយពីមានការពិភាក្សាយ៉ាងល្អិតល្អន់ អង្គប្រជុំបានសម្រេច កែសម្រួលពាក្យពេចន៍ បំពេញបន្ថែម និងលុបចោលខ្លឹមសារមួយចំនួន ចាប់ពីមាត្រា៧ ដល់មាត្រា១៤ ដូចខាងក្រោម ៖

**មាត្រា៧**

គូភាគី លុបពាក្យ (~~ត្រូវ~~) ជំនួសដោយពាក្យ (នឹង) ធ្វើការពិគ្រោះយោបល់ជាទៀលរាល់ឆ្នាំ ឬតាមការចាំបាច់ ដើម្បីវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត លុបពាក្យ (~~ក្រោម~~) អនុស្សរណៈនៃការយោគយល់ ដើម្បីកែសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការ។

**មាត្រា៨**

វាក្យខណ្ឌនេះលុបទាំងស្រុង (~~វិវាទដែលអាចកើតចេញពីការបកស្រាយ ឬការអនុវត្តអនុស្សរណៈត្រូវដោះស្រាយក្នុងស្មារតីមិត្តភាព តាមរយៈការពិគ្រោះយោបល់រវាងអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៤ វាក្យខណ្ឌទី១ និងតាមរយៈការចរចាតាមផ្លូវការទូត~~)។

រាល់វិវាទ បន្ថែមពាក្យ (ដែល) កើតឡើងរវាងគូភាគី លុបពាក្យ (~~ពាក់ព័ន្ធនឹងការ~~) ពីការបកស្រាយ ឬការអនុវត្តអនុស្សរណៈនៃការយោគយល់នេះ ត្រូវដោះស្រាយដោយគូភាគីក្នុងស្មារតីមិត្តភាពតាមរយៈ លុបពាក្យ (~~ផ្លូវ~~) ការទូត។

**មាត្រា៩**

វាក្យខណ្ឌនេះលុបទាំងស្រុង ~~អនុស្សរណៈ អនុស្សរណៈនៃការយោគយល់នេះមិនប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការផ្លូវច្បាប់រវាងគូភាគី ក្នុងកិច្ចការងារបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមកលើវិស័យព្រហ្មទណ្ឌ។~~

លុបពាក្យ (~~អនុស្សរណៈ~~) អនុស្សរណៈនៃការយោគយល់នេះ មិនប៉ះពាល់សិទ្ធិ ឬកាតព្វកិច្ចរបស់គូភាគីកើតចេញពីកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត លុបឃ្លា (~~ដែលភាគីនីមួយៗបានចុះហត្ថលេខារួចហើយ~~) ដែលខ្លួនជាភាគីនោះឡើយ។

**មាត្រា១០**

ការចំណាយផ្សេងៗសម្រាប់ដំណើរការសំណើក្រោមអនុស្សរណៈ បន្ថែមពាក្យ (នៃការយោគយល់) នេះជាបន្ទុករបស់ភាគីស្នើសុំ ឬធ្វើឡើងតាមការព្រមព្រៀងរបស់គូភាគី។

វាក្យខណ្ឌនេះលុបទាំងស្រុង

~~ភាគីទទួលសំណើទទួលបន្ទុកលើការចំណាយទូទៅកើតចេញពីការអនុវត្តសំណើ សុំកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈនៃការយោគយល់នេះ ។ ក៏ប៉ុន្តែ ក្នុងករណីការអនុវត្តតម្រូវឱ្យមានការចំណាយណាផ្សេងក្រៅពីការចំណាយទូទៅ គូភាគីនឹងធ្វើការពិគ្រោះយោបល់ ដើម្បីកំណត់លក្ខខណ្ឌស្របតាមសំណើសុំកិច្ចសហប្រតិបត្តិការនេះ។~~

**មាត្រា១១**

ភាគីនីហ្សេរីយ៉ាបន្ថែមមាត្រាថ្មី

វាក្យខណ្ឌនេះលុបទាំងស្រុង (~~សំណើសុំកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈនៃការយោគយល់នេះត្រូវធ្វើឡើងជាអក្សរខ្មែរ និងអក្សរអង់គ្លេស (រមជាមួយសំណៅបកប្រែ)។~~

**មាត្រា១២**

លុបពាក្យ (~~អនុស្សរណៈ~~) អនុស្សរណៈនៃការយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយគូភាគី និងមានសុពលភាពរយៈពេលបី (០៣) ឆ្នាំ។

បន្ទាប់មកត្រូវពន្យារជាស្វ័យប្រវត្តិតែម្តងទៀតសម្រាប់រយៈពេលបី (០៣)ឆ្នាំ បើសិនភាគីទាំងពីរគ្មានការជំទាស់ទេ។

វាក្យខណ្ឌនេះលុបទាំងស្រុង (~~អនុស្សរណៈនេះមានសុពលភាពរយៈពេលបី (០៣)ឆ្នាំ។ ភាគីម្ខាងអាចជូនដំណឹងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរតាមរយៈស្ថានទូតក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈនេះ។ ក្នុងករណីនេះ អនុស្សរណៈនេះនឹងបញ្ចប់ក្នុងរយៈពេលបី (០៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។ ការបញ្ចប់អនុស្សរណៈនេះមិនមានផលប៉ះពាល់ដល់ការអនុវត្តភារកិច្ចដែលមិនទាន់បានបញ្ចប់ទាំងឡាយណា ដែលបានព្រមព្រៀងគន្លងមកនោះទេ~~)។

ភាគីនីមួយៗ អាចបញ្ចប់អនុស្សរណៈនៃការយោគយល់នេះនៅពេលណាក៏បាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរជូនភាគីម្ខាងទៀតតាមរយៈ លុបពាក្យ (~~ផ្លូវ~~) ការទូត។

ការបញ្ចប់ មានប្រសិទ្ធភាពអនុវត្តក្នុងរយៈពេលបី (០៣) ខែ ចាប់ពីថ្ងៃទទួលបានការជូនដំណឹង។

វាក្យខណ្ឌនេះលុបទាំងស្រុង

(~~ក្រោយអនុស្សរណៈនេះចូលជាធរមាន ភាគីម្ខាងអាចស្នើភាគីម្ខាងទៀតសុំធ្វើវិសោធនកម្ម ឬបំពេញបន្ថែមលើអត្ថបទអនុស្សរណៈនេះបាន។ វិសោធនកម្ម ឬការបំពេញបន្ថែមត្រូវមានការព្រមព្រៀងរវាងគូភាគី នឹងត្រូវចូលជាធរមានស្របតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ~~)។

**មាត្រា១៣**

ភាគីនីហ្សេរីយ៉ាបន្ថែមមាត្រាថ្មី

លុបពាក្យ (~~ភាតព្វកិច្ច~~) ជំនួសដោយពាក្យ (កិច្ចសហប្រតិបត្តិការ) កំពុងអនុវត្ត និងនៅជាធរមាន លុបពាក្យ (~~ជំនួយ~~) ជំនួសដោយពាក្យ (កិច្ចសហប្រតិបត្តិការ) ដែលបានចាប់ផ្តើមអនុវត្តរួចហើយ និងបន្ត លុបពាក្យ (~~គោរព~~) ជំនួសដោយពាក្យ (**អនុវត្ត**) តាមអនុស្សរណៈនៃការយោគយល់នេះ បន្ថែមឃ្លា (**ត្រូវបន្តអនុវត្តឱ្យបានចប់សព្វគ្រប់**) ទោះបី លុបពាក្យ (~~ក្រោយពេល~~) ជំនួសដោយពាក្យ (អនុស្សរណៈនេះ) បញ្ចប់ បន្ថែមពាក្យ (**ក៏ដោយ**)។

**មាត្រា១៤ អង្គប្រជុំបានឯកភាពរក្សានូវខ្លឹមសារដើម ។**

ជាកិច្ចបញ្ចប់អង្គប្រជុំបានឯកភាពគ្នា រៀបចំធ្វើរបាយការណ៍គោរពជូន **ឯកឧត្តមអតិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្នើសុំគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់ ថាតើគួរធ្វើលិខិតទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក៏ត្រូវឱ្យក្រុមការងារបច្ចេកទេស ដើម្បីធ្វើការពិភាក្សាជាមួយភាគីនីហ្សេរីយ៉ាមួយជំហានសិន? ក្នុងករណីដែល **ឯកឧត្តមអតិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ណែនាំឱ្យក្រុមការងារបន្តជួបពិភាក្សាជាមួយភាគីនីហ្សេរីយ៉ា នោះតំណាងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានជាអ្នកសម្របសម្រួលលើការងារនេះ ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២៣

**អ្នកធ្វើកំណត់ហេតុ**

**វរសេនីយ៍ទោ ហ៊ិន ហ៊ា**

**បានឃើញ និងឯកភាព**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ កត្តិក ឆ្នាំថោះ ចត្វាស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២៣

**ប្រធានអង្គប្រជុំ**

**អ៊ូច ចាន់ណូរ៉ា**